ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែ សីហា ឆ្នាំ ២០១០



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវៈសាស្ត្រ អាវុធវិទ្យុសកម្ម | ២ |
| ៣- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី | ៣ |
| ៤- | កិច្ចប្រជុំឡើងវិញលើ៖<br>១- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ<br>២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិភាសាខ្មែរ | ៤ |
| ៥ | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កក្កដា ឆ្នាំ២០១០ | ៥ - ៩ |
| ៦ | សកម្មភាពដ៏ទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ - ១៣ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំ ជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) និងឯកឧត្តម **អ៊ុក ភូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ ***សេចក្តីព្រាងអនុក្រឹត្យស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី*** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានអគ្គិសនីកម្ពុជា សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិក នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



យោងតាមសំណើរបស់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ដើម្បីឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្ស និសិត្ស និងដើម្បីចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យបានរីកចម្រើន។

ចំពោះការប្រែក្លាយនេះ វិទ្យាស្ថានមានទីតាំងច្បាស់លាស់ មានមូលដ្ឋានសម្ភារៈគ្រប់គ្រាន់អាចដំណើរការបណ្តុះបណ្តាលបាន និងមានសាស្ត្រាចារ្យមានបទពិសោធន៍ និងមានសញ្ញាបត្រខ្ពស់។

វិទ្យាស្ថាននេះ នឹងធ្វើការបណ្តុះបណ្តាល៖
- ថ្នាក់វិញ្ញាបនបត្រ សិក្សារយៈពេលខ្លីក្រោម ១ឆ្នាំ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ ២ឆ្នាំ និង ៣ឆ្នាំ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ។

ចាប់ពីឆ្នាំ២០០១ ដល់ ឆ្នាំ២០១០ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា បានបណ្តុះបណ្តាលសិក្ខាកាមចំនួន ៨៣៤៤នាក់ និងនិសិត្សថ្នាក់បច្ចេកទេសជាន់ខ្ពស់ចំនួន ៦៨០នាក់[១]។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះ កាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

*[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជា វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គសនី៕*

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម

កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្ដម **គីម សយសាម៉ាឡែន** អនុ-ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្ដម **អ៊ុក ភូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហ-ប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ ***សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម*** ដោយមានការអញ្ជើញចូលរួមពី តំណាងអាជ្ញាធរជាតិអាវុធគីមី សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិក នៃក្រុម-ប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គ-លេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។



យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា " ត្រូវហាមឃាត់ដាច់ខាតរាល់ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមីឬអាវុធវេគ្រាណូ" ។ កន្លងមករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តឱ្យប្រើប្រាស់ច្បាប់ស្ដីពី ការហាមឃាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដែលក្នុងមាត្រា៩ បានចែងថា " ការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ" ហេតុដូចនេះ អាជ្ញាធរជាតិអាវុធគីមី បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការកំណត់សារជាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម សម្រាប់ជាយន្តការដើម្បីធ្វើការត្រួតពិនិត្យ ការគ្រប់គ្រង ការប្រមូលទិន្នន័យ ស្ដីពីតម្រូវការសារជាតុគីមីសម្រាប់ប្រើប្រាស់ផ្នែកឧស្សាហកម្ម និងបម្រើគោលដៅសន្តិភាព ស្របតាមវិធានការផែនការសកម្មភាពនៃការអនុវត្តអនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ និងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋភាគីដទៃទៀតឱ្យមានប្រសិទ្ធិភាពខ្ពស់[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្ដីព្រាងអនុក្រឹត្យនេះយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្ដីព្រាងនេះកាន់តែសុក្រឹត្យ។ ក៏ប៉ុន្តែនៅមានចំណុចខ្លះនៅមិនទាន់ឯកភាពគ្នា។ ដូច្នេះ អង្គប្រជុំបានប្រគល់សិទ្ធិជូនសាមីស្ថាប័ន ចង់កែសម្រួលតាមស្មារតីអង្គប្រជុំ ឬក៏ចង់រក្សាទុកពិភាក្សាម្ដងទៀតនៅពេលប្រជុំអន្តរក្រសួង។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ៕

---

*[១] អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុស្ដីពី សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់សារជាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម៕*

## កិច្ចប្រជុំបន្តលើសេចក្ដីព្រាងច្បាប់ស្ដីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី



កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងយុត្តិធម៌ សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិក នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាបន្តលើ សេចក្ដីព្រាងច្បាប់នេះ ដោយរលូនរហូតដល់ចប់។ ជាចុងក្រោយអង្គប្រជុំ បានស្នើឱ្យក្រសួងសាមីកែសម្រួលតាមស្មារតីអង្គប្រជុំទាំង ៥លើកកន្លងមក។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ។



## កិច្ចប្រជុំឡើងវិញលើ៖

### សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ

### និងសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិភាសាខ្មែរ

កាលពីថ្ងៃទី១០ និងទី១២ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆ្វរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាឡើងវិញលើ ***១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ ២-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិភាសាខ្មែរ*** ដោយមានការអញ្ជើញចូលរួមពីតំណាងគណៈកម្មាធិការជាតិភាសារខ្មែរ សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិក នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រី ជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឭកថា សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០។ អង្គប្រជុំនៅពេលនោះ បានសម្រេចលើកពេលទៅថ្ងៃក្រោយ ដើម្បីទុកពេលវេលាសិក្សាឱ្យបានស៊ីជម្រៅសិន។




អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងព្រះរាជក្រឹត្យ និងអនុក្រឹត្យនេះយ៉ាងយកចិត្តទុកដាក់ ហើយបានសម្រេច កែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែរលូន។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះ ៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កក្កដា ឆ្នាំ ២០១០



កាលពីថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំកិច្ចប្រជុំទូលាយនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ក្រោមអធិបតីភាពឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ **កក្កដា** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➢ *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងខែកក្កដាឆ្នាំ២០១០នេះ កើនឡើង 0.៥% បើធៀបនឹងខែមិថុនា និងកើនឡើង ១.៦% ក្នុងរយៈពេល១២ខែ។ បើប្រៀបធៀបរយៈពេល ៧ ខែដូចគ្នា ឆ្នាំ ២០១០/២០០៩ សន្ទស្សន៍ថ្លៃមធ្យមនៃទំនិញប្រើប្រាស់គ្រប់មុខ កើនឡើង ៤.៩% ។*

➢ *បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ(កក្កដា/មិថុនា) បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖*

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង<br>(ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ<br>(ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ▪ ម្ហូបអាហារៈ +១.0% (+១.៤% )<br>▪ គ្រឿងសង្ហារឹម និងសំភារៈប្រើប្រាស់ៈ +0.៤% (+0.៦% )<br>▪ សុខាភិបាលៈ +0.២% (–២.៧%)<br>▪ ការដឹកជញ្ជូនៈ 0.១% (+៤.៨%)<br>▪ ការកំសាន្ត និងវប្បធម៌ៈ 0.២% (+១.៧%)<br>▪ ភោជនីយដ្ឋានៈ 0.៧% (**–២.២%**)<br>▪ ទំនិញ និងសេវាកម្មផ្សេងទៀតៈ 0.១% (+៨.៩%) | ▪ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ៈ –0.៣% (+១.២%)<br>▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀតៈ –0.៣% (+៣.៤%) |

➢ ក្នុងខែកក្កដាឆ្នាំ២០១០នេះ អត្រាប្តូរប្រាក់ **៛/ដុល្លារ** ស្មើនឹង **៤,២៣៧៛/១ដុល្លារ** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក 0.៤% និងចុះថោក ១.២% ក្នុងរយៈពេល១២ខែ ។ អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣១៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក 0.៨% ធៀបនឹងបាត និងចុះថោក ៦.៥% ក្នុងរយៈពេល១២ខែ។ អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **0.២២២៛/១ដុង** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក **0.៥%** ប៉ុន្តែ**ឡើងថ្លៃ ៥.៥%** ក្នុងរយៈពេល១២ខែ។

## ២) ស្ថានភាពថវិកាជាតិ

➢ យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុង**ខែ**កក្កដា**ឆ្នាំ**២០១០**នេះ អនុវត្តបាន**ចំនួន ៥២៤ ពាន់លានរៀល (ជាមធ្យមប្រចាំខែស្មើនឹង ៧៣% នៃគម្រោង) ក្នុងនោះ ចំណូលមូលធន ១០.៧ ពាន់លានរៀល (ជាមធ្យមប្រចាំខែស្មើនឹង ១២% នៃគម្រោង) និងចំណូលចរន្ត ៥១៣.៣ ពាន់លានរៀល (ជាមធ្យមប្រចាំខែស្មើនឹង ៩៨% នៃគម្រោង) ។

➢ *បើធៀបនឹងខែមុន* ***ចំណូលថវិកាជាតិ****ខែកក្កដាកើនឡើង ២៩% **និង**កើនឡើង ១២% ក្នុងរយៈពេល១២ខែ ។* ការកើនឡើង២៩% នេះ បណ្តាលមកពីចំណូលមូលធនកើនឡើង ៣១% និងចំណូលចរន្តកើនឡើង ២៩%។

- ក្នុងចំណូលចរន្តនាខែកក្កដានេះ ចំណូលសារពើពន្ធកើនឡើង២៥% និងចំណូលមិនមែនសារពើពន្ធកើនឡើង ៩៦%។

| ក្នុងចំណូលសារពើពន្ធ | ក្នុងចំណូលមិនមែនសារពើពន្ធ |
|---|---|
| ✓ ពន្ធ និងអាករគយកើនឡើង៥.៩%<br>✓ ចំណូលពន្ធដារកើនឡើង៤០%<br>✓ ចំណូលសារពើពន្ធផ្សេងៗកើនឡើង២០% | ✓ ទេសចរ ថយចុះ ៨៣%<br>✓ សម្បទានរ៉ែ កើនឡើង ១.២%<br>✓ អាកាសចរណ៍ស៊ីវិលថយចុះ ៤៥%<br>✓ ផលទុនទេសចរណ៍ ថយចុះ ៤.៩%<br>✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ កើនឡើង៧៣%<br>✓ អាករស្ពានទូត កើនឡើង១០%<br>✓ ជួលរោងចក្រ សហគ្រាសកើនឡើង១០០%<br>✓ ការលក់អចលនកម្ម ថយចុះ៣៥% |

➢ ***ចំណាយថវិកាជាតិ*** នៅខែកក្កដា ឆ្នាំ២០១០នេះ អនុវត្តបាន **៦៣៦.៧ពាន់លានរៀល** (ជាមធ្យមប្រចាំខែ ស្មើនឹង ៦៣%នៃគម្រោង) ក្នុងនោះ **ចំណាយចរន្ត ៥២៤.០ ពាន់លានរៀល** និង**ចំណាយមូលធន ១១២.៧ពាន់លានរៀល**។

➢ *បើធៀបនឹងខែមុន* ***ចំណាយថវិកាជាតិកើនឡើង ២៨%*** *ប៉ុន្តែថយចុះ២.១% ក្នុងរយៈពេល១២ខែ ។* ការកើនឡើងនេះ គឺបណ្តាលមកពីចំណាយចរន្ត***កើនឡើង ៣៩%*** ។ រីឯចំណាយមូលធន*ថយចុះ៤.១%*។

➢ ***តុល្យភាពថវិកាជាតិក្នុងខែកក្កដានេះមានឱនភាពចំនួន ១១២.៧ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុ

➢ ក្នុងខែកក្កដាឆ្នាំ ២០១០ **រូបិយវត្ថុ** M2 មានចំនួន ***១៨,៥១១ពាន់លានរៀល កើនឡើង១.៣%*** ធៀបនឹងខែមុន និង***កើនឡើង ៣១%*** ក្នុងរយៈពេល១២ខែ ។ ***ការកើនឡើងនៃ*** M2 ***នាខែនេះបណ្តាលមកពី ការកើនឡើងនូវ ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ៦.៤% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង២.០%*** ។ *ចំណែកឯ* ***រូបិយវត្ថុក្រៅធនាគារ ថយចុះ១.៥%*** និង***ប្រាក់បញ្ញើចរន្ត ថយចុះ២០%*** ។

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែកក្កដាឆ្នាំ ២០១០នេះ មានចំនួន**២,៣៥០ លានដុល្លារ *ថយចុះ១.៧%***ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ៦.៧% ក្នុងរយៈពេល១២ខែ។

➢ ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែកក្កដាឆ្នាំ ២០១០ មានចំនួន **២,៣០៣ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧០ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៥៧៣ ពាន់លានរៀល**។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិមានការកើនឡើងជាប្រចាំចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៩មក*** ឯក្នុងខែកក្កដាឆ្នាំ ២០១០នេះ មានចំនួន **៧,៣១៥ ពាន់លានរៀល** កើនឡើង ១.៥% បើធៀបនឹងខែមុន និងកើនឡើង ៣៦% ក្នុងរយៈពេល ១២ខែ។

➢ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជជារួមមានការកើនឡើងជារៀងរាល់ខែ ចាប់ពីដើមឆ្នាំ២០១០មក*** ឯក្នុងខែកក្កដានេះមានចំនួន ១២,១៤៤ ពាន់លានរៀល កើនឡើង ២.៩% បើធៀបនឹងខែមុន និងកើនឡើង ២១% ក្នុងរយៈពេល១២ខែ។

➢ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មានចំនួន **១,៤៥០ ពាន់លានរៀល** កើនឡើង ៤.៥% បើធៀបនឹងខែមុន និងកើនឡើង ៣១% ក្នុងរយៈពេល១២ខែ។

➢អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារពាណិជ្ជទាំងអស់) ស្មើនឹង ៦.០% ស្ថិតនៅស្ថិរ ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១៤% ក្នុង រយៈពេល១២ខែ។

➢អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជក្នុងខែកក្កដានេះស្មើនឹង **៤.៥១%** ថយចុះ ៣.៤% ធៀបនឹងខែមុន និងថយចុះ ២៥% ក្នុងរយៈពេល១២ខែ។

### ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ កសិកម្ម: ខែកក្កដា

- ផលិតកម្មនេសាទចំនួន **៣៥ ពាន់តោន** ថយចុះ ៣៨% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល១២ខែ។

➢ ឧស្សាហកម្ម: ខែកក្កដា

- ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១,១២៨ពាន់លានរៀល (បានពី១៦៦រោងចក្រ)។
- ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៩៤.៥លានគីឡូវ៉ាត់ម៉ោង កើនឡើង 0.៨% បើធៀបនឹងខែមុន និងកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។

➢ សំណង់: ខែកក្កដា

- **សំណង់អនុញ្ញាតឲ្យសាងសង់** មានចំនួន ២២៤.៩ពាន់ម² កើនឡើង ៩.៥% បើធៀបនឹងខែមុន និង កើនឡើង ៦៤% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ៧៦.៨លានដុល្លារ កើនឡើង ៣២% បើធៀបនឹងខែមុន និងកើនឡើង ៨៩% ក្នុងរយៈពេល ១២ខែ។
- **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (២៩%នៃសំណង់អនុញ្ញាតសរុប) ពាណិជ្ជកម្ម (៣១%នៃសំណង់អនុញ្ញាតសរុប) និងទេសចរណ៍ (១៥%នៃសំណង់អនុញ្ញាតសរុប)។

➢ វិនិយោគ: នាខែកក្កដានេះគម្រោងវិនិយោគអនុញ្ញាតិដោយ គ.វ.ក. មានចំនួន **១១**។ បើគិតជា ទុនវិនិយោគ មានទឹកប្រាក់ស្មើនឹង **២១២ លានដុល្លារ** កើនឡើង ៣២០% បើធៀបនឹងខែមុន។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **១៤.៤ពាន់នាក់**។

➢ សេវាកម្ម និងទេសចរណ៍: ខែកក្កដា

- **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្មមានចំនួន ២៥៨ កើនឡើង ២៣% បើធៀបនឹងខែមុន
- **ការដាក់ពាក្យរកការងារទៅក្រៅប្រទេសនៅក្រសួងការងារ**មានចំនួន ៣,៩៩៥នាក់ កើនឡើង ៥.៨% បើធៀបនឹងខែមុន និងកើនឡើង ១៣៤% ក្នុងរយៈពេល ១២ខែ។
- អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុនមានចំនួន ៧,០៨០នាក់ កើនឡើង ៨៦% បើធៀបនឹងខែមុន និងកើនឡើង ៣១៩% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះទទួលបានការងារក្នុងប្រទេស មានចំនួន ១,៦០២នាក់ និងទទួលបានការងារក្រៅប្រទេស មានចំនួន ៥,៤៧៨នាក់។
- **ទំនិញឆ្លងកាត់តាមផ្លូវសមុទ្រ** (សរុប៦ផែ) មានចំនួន ៣៣១.៤ ពាន់តោន ថយចុះ ១.៧% បើធៀបនឹងខែមុន និង ថយចុះ ៩.៣% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ
  - ទំនិញឆ្លងកាត់ផែកំពង់សោម កើនឡើង ៤.៨% ធៀបនឹងខែមុន និងកើនឡើង ១.១% ក្នុងរយៈពេល១២ខែ
  - ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុងថយចុះ ២.៨% បើធៀបនឹងខែមុន និងថយចុះ ២៣% ក្នុងរយៈពេល១២ខែ
  - ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុងថយចុះ ៨២% បើធៀបនឹងខែមុន និងថយចុះ ៩៤% ក្នុងរយៈពេល១២ខែ
  - ទំនិញឆ្លងកាត់ផែភ្នំពេញថយចុះ ៤.២% ប៉ុន្តែកើនឡើង ៤.៥% ក្នុងរយៈពេល១២ខែ
- **អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ២២៦ពាន់នាក់ កើនឡើង ២១% បើធៀបនឹងខែមុន និងកើនឡើង ១៧% ក្នុងរយៈពេល១២ខែ។
- **ចំនួនអ្នកទេសចរកម្ពុជាចេញក្រៅប្រទេស**មាន៤៤ពាន់នាក់កើនឡើង ១៨% បើធៀបនឹងខែមុន និងកើនឡើង ៧២% ក្នុងរយៈពេល ១២ខែ។
- **ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា**មាន ២០២ ពាន់នាក់ កើនឡើង ២២% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវអាកាសមាន **៩៨ពាន់នាក់** កើនឡើង ២២% បើធៀបនឹងខែមុន និងកើនឡើង ១៧% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវគោក និងទឹកមាន **១០៥ពាន់នាក់** កើនឡើង ២១% បើធៀបនឹងខែមុន និងកើនឡើង ៣៧% ក្នុងរយៈពេល១២ខែ។

▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិមានចំនួន **៤,៤២៧នាក់** កើនឡើង ៣១% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ៩% ក្នុងរយៈពេល១២ខែ។

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➢យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែកក្កដាឆ្នាំ២០១០ មានចំនួន ២,០៦៥ ពាន់លានរៀល បើធៀបនឹងខែមុន កើនឡើង ១៩% និងកើនឡើង ៥៣% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ :

| ទំនិញដែលកើនឡើង (កក្កដា/មិថុនា) | ទំនិញដែលថយចុះ (កក្កដា/មិថុនា) |
|---|---|
| - ឧស្ម័ន +១៨% | - ប្រេងឥន្ធនៈ –៣៩% |
| - ដែកសំណង់ +៦៨% | - ស៊ីម៉ង់: –២.៤% |
| - គ្រឿងអេឡិចត្រូនិច +៣២% | - ត្រាក់ទ័រនិងគោយន្ត –២៦% |
| - រថយន្តសរុប (ពាន់លានរៀល) +១៨% | - ម៉ូតូ –៦៧% |
| - ស្រូវសាលី +១៤% | - អង្ករ –២៧% |
| - ជីនិងថ្នាំកសិកម្ម +៥៩% | - ផ្លែឈើនិងបន្លែ –១០% |
| - ស្ករស +៣៣% | - ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ –១២% |
| - ភេសជ្ជៈ +១១៥% | |

➢ **ការនាំចេញ** ក្នុងខែកក្កដាឆ្នាំ ២០១០ មានចំនួន ១,៦៥៥ពាន់លានរៀល ថយចុះ ១២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៩% ក្នុងរយៈពេល១២ខែ។ ក្នុងនោះការកើនឡើងចំពោះការនាំចេញមាន ផលិតផលឈើកែច្នៃ ៤៨% ផលិតផលវាយនភណ្ឌនិងស្បែកជើង ២៨% អង្ករ ៥៨% កៅស៊ូ ៣៧%។ ការនាំចេញផលិតផលនេសាទ ក្នុងខែនេះ ថយចុះ ៣៦% បើធៀបនឹងខែមុន ។

➢ *ក្នុងខែកក្កដាឆ្នាំ២០១០នេះជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៤១១ពាន់លានរៀល។*

## ៦. កំណត់សម្គាល់សំខាន់ៗ

៦.១. បញ្ហាសំខាន់ៗ នៃស្មារតីអង្គប្រជុំ

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:***

១) រូបិយវត្ថុ: ក្នុងឆ្នាំ ២០១០នេះ ស្ថានភាពរូបិយវត្ថុកម្ពុជាទទួលរងនូវឥទ្ធិពលអវិជ្ជមានមួយចំនួន ពីលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច។ រូបិយវត្ថុក្រៅធនាគារនាខែកក្កដានេះ ថយចុះ ១.៥% ធៀបនឹងខែមុន និងថយចុះ ៣% បើធៀបនឹងខែធ្នូ ឆ្នាំ២០០៩។ ក្នុងរយៈពេល ៧ខែ (ធ្នូ២០០៩–កក្កដា២០១០) ចំនួនប្រាក់រៀលក្រៅធនាគារ បើគិតសមមាត្រនឹង M2 មានការថយចុះពី ១៨.៥% នៃ M2 មកត្រឹម ១៥.៦% នៃ M2 ប៉ុណ្ណោះ។ ការនេះបណ្តាលមកពីធនាគារជាតិនៃកម្ពុជា ធ្វើនិយតកម្មក្នុងទីផ្សាររូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថានភាពថ្លៃ និងអត្រាប្តូរប្រាក់។ ក្នុងរយៈពេល៧ខែដើមឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ដេញថ្លៃលក់រូបិយបណ្ណសរុបចំនួនជាង ៤៤លានដុល្លារ ដើម្បីស្រូបទាញយកប្រាក់រៀលចូលប្រព័ន្ធធនាគារវិញ។

២) អគ្គិសនីផលិតដោយវារីអគ្គិសនី: វារីអគ្គិសនីមាននិន្នាការថយចុះគួរឲ្យចាប់អារម្មណ៍ និងបរិមាណផលិតកម្មដែលអនុវត្តបានទាបជាងផែនការដែលរំពឹងទុក។

## ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដា ឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឱ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. អាករនាំចេញ | +៥៤% | +២០០% | – |
| ២. អាករលើផលរបរ | +៥៧៣% | +៥៧៣% | – |
| ៣. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | +៦៦៧% | –៧១% | – |
| ៤. ប្រាក់បញ្ញើបរន្ត | –២០% | +២៣% | – |
| ៥. ផលិតកម្មនេសាទ | +៨៤% | +១៥% | – |
| ៦. ការអនុញ្ញាតសំណង់ពាណិជ្ជកម្ម | +៤៥៣% | +១៣៥% | – |
| ៧. ការអនុញ្ញាតសំណង់ទេសចរណ៍ | +២០១% | +៦០៥% | – |
| ៨. អគ្គិសនីផ្គត់ផ្គង់ដោយរ៉ាអគ្គិសនី | –៣២% | –៨៧% | កំពស់ទឹកភ្លៀងទាបនៅតំបន់ខ្ពង់រាប ការថយចុះនៃព្រៃឈើ |
| ៩. នាំចេញផលិតផលឈើកែច្នៃ | +៤៨% | +១៦៧៥% | – |
| ១០. នាំចេញអង្ករ | +៥៨% | +១២០១% | – |



# សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ សីហា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.០៨.១០ ព្រឹក | ដឹកនាំអង្គប្រជុំជាមួយក្រុមប្រឹក្សាភិបាលសិប្បករអង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៤.០៨.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលកោះពេជ្រ។ |
| ៣ | ០៥.០៨.១០ ព្រឹក | ដឹកនាំអង្គប្រជុំទូលាយ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១០។ |
| ៤ | ០៩.០៨.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្សព្វផ្សាយកម្មវិធី សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ សម្រាប់រយៈពេល ១០ឆ្នាំ (២០១០-២០១៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលកោះពេជ្រ។ |
| ៥ | ០៩.០៨.១០ ល្ងាច | ដឹកនាំអង្គប្រជុំគណៈកម្មការរៀបចំការដេញថ្លៃសាងសង់អគារមជ្ឈមណ្ឌលដំកល់ឯកសារច្បាប់ ក្នុងអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា និងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១១.០៨.១០ ល្ងាច | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើ៖<br><br>១- អនុក្រឹត្យស្តីពី ការកំណត់អត្រា និងបែបបទ នៃការជ្រើសរើសជនពិការចូលបម្រើការងារ។<br>២- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាន និងសុខភាព។<br>៣- បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ន ពីស្ថាប័ននីតិប្បញ្ញត្តិលើ កិច្ចព្រមព្រៀងស្តីពី បត្យាប័នរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។<br><br>សម្រាប់ត្រៀមប្រជុំជាមួយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១២.០៨.១០ ព្រឹក | ចូលរួមជាអធិបតីក្នុងមហាសន្និបាតសមាគមសង្គហសង្គម អាណត្តិទី១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកិត្តិយសនៃសមាគមសង្គហសង្គមទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ។ |
| ៨ | ១២.០៨.១០ ល្ងាច | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយសម្រាប់ត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br><br>១- អនុក្រឹត្យស្តីពី ការកំណត់អត្រា និងបែបបទ នៃការជ្រើសរើសជនពិការចូលបម្រើការងារ។<br>២- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាន និងសុខភាព។<br>៣- បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ន ពីស្ថាប័ននីតិប្បញ្ញត្តិលើ កិច្ចព្រមព្រៀងស្តីពី បត្យាប័នរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១៧.០៨.១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយឯកសារគោលនយោបាយ ស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ |
| ១០ | ១៧.០៨.១០<br>ម៉ោង ១៥:០០ | ប្រជុំពិភាក្សាការងារជាមួយ ក្រុមហ៊ុនសាងសង់វិស្វកម្មយូណាន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៧.០៨.១០<br>ម៉ោង ១៧:០០ | ប្រជុំជាមួយ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌា ដើម្បីពិភាក្សាអំពីកម្មវិធីដំណោះក្នុងពិធីបញ្ចុះបឋមសិលា សម្រាប់គម្រោងសាងសង់សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ីនៅបូរីវប្បធម៌ និងទេសចរណ៍ក្នុងខេត្តសៀមរាបនៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៩.០៨.១០ ព្រឹក | ប្រជុំពិភាក្សាការងារជាមួយ អាទីហ្សង់អង្គរ នៅខេត្តសៀមរាប។ |
| ១៣ | ២០.០៨.១០ ព្រឹក | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br><br>១- អនុក្រឹត្យស្តីពី ការកំណត់អត្រា និងបែបបទ នៃការជ្រើសរើសជនពិការចូលបម្រើការងារ។<br>២- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាន និងសុខភាព។<br>៣- បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ន ពីស្ថាប័ននីតិប្បញ្ញត្តិលើ កិច្ចព្រមព្រៀងស្តីពី បត្យាប័នរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។ |
| ១៤ | ២០.០៨.១០ ល្ងាច | ចូលរួមប្រជុំគណៈកម្មការសាងសង់មជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២២.០៨.១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង ជូនគណៈប្រតិភូសមាជិកសភាជប៉ុន ក្រោមការរៀបចំឡើងដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅគេហដ្ឋានរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** និងលោកជំទាវ។ |
| ១៦ | ២៣.០៨.១០ ល្ងាច | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឱ្យឯកឧត្តម ISHIZEKI TAKASHI សមាជិកសភាជប៉ុន ចូលជួបសវនាការ៖<br><br>១-ស្វែងយល់អំពីដំណើរការសេដ្ឋកិច្ចកម្ពុជា។<br>២-តួនាទីរបស់រដ្ឋាភិបាលជប៉ុន និងវិស័យឯកជនជប៉ុន ក្នុងការជួយអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ |
| ១៧ | ២៥.០៨.១០ ព្រឹក | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- អនុក្រឹត្យស្តីពី ការប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារ។<br>២- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិជនពិការ។<br>៣- បញ្ហាផ្សេងៗ<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | ២៧.០៨.១០ ល្ងាច | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ។<br>២- អនុក្រឹត្យស្តីពី ការបង្កើតតំបន់គ្រប់គ្រង និងការអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀតស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត។<br>៣- បញ្ហាផ្សេងៗ<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ៣០.០៨.១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយសម្រាប់ត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ។<br>២- អនុក្រឹត្យស្តីពី ការបង្កើតតំបន់គ្រប់គ្រង និងការអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀតស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត។<br>៣- បញ្ហាផ្សេងៗ |
| ២០ | ៣១.០៨.១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសជាផ្លូវការ វេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ និងការសម្ពោធគេហទំព័រផ្សព្វផ្សាយថ្មីរបស់ក្រសួងទេសចរណ៍ www.tourismcabodia.org ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ នៅសណ្ឋាគារណាហ្គាវើល។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គីម សយសាម៉ាឡែន អនុប្រធាន ECOSOCC ប្រចាំខែ សីហា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៦.០៨.១០ | ចរចាកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយ ADB ស្តីពីកម្មវិធីពិពិធភាពសេដ្ឋកិច្ច (PED) អនុកម្មវិធី២ (Subprogram2)។ |
| ២ | ១៧.០៨.១០ | កិច្ចប្រជុំបូកសរុប និងពិធីចុះហត្ថលេខាលើ Minute of the Meeting កិច្ចចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន PED - Subprogram2។ |
| ៣ | ១៧.០៨.១០ | កិច្ចប្រជុំអនុម័តលើ RIA Strategic Plan និងសេចក្តីសម្រេចបង្កើត ORIA (ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី)។ |
| ៤ | ២៣.០៨.១០ | កិច្ចប្រជុំក្រុមការងារអនុវត្តគម្រោង RIA PIWG។ |
| ៥ | ២៦.០៨.១០ | កិច្ចប្រជុំគណៈដឹកនាំ ECOSOCC។ |
| ៦ | ៣១.០៨.១០ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសជាផ្លូវការ វេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ និងការសម្ពោធគេហទំព័រផ្សព្វផ្សាយថ្មីរបស់ក្រសួងទេសចរណ៍ www.tourismcabodia.org ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ នៅសណ្ឋាគារណាហ្គាវើល។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC ប្រចាំខែ សីហា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧.០៨.១០ | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍របស់គណៈប្រតិភូ ត្រឡប់មកពីចូលរួមកិច្ចប្រជុំលើកទី ៣៤ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ទៅទីក្រុងប្រេស៊ីលីយ៉ា ប្រទេសប្រេស៊ីល ដឹកនាំដោយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ។ |
| ២ | ១១.០៨.១០ | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធិផលនានា វត្តអង្គប្រាសាទធ្លាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តអង្គប្រាសាទធ្លាយមានជ័យ ខេត្តកណ្តាល។ |
| ៣ | ២៦.០៨.១០ | ចូលរួមជាកិត្តិយសដើម្បីធ្វើបទអន្តរគមន៍ស្តីពី ការរីកចម្រើនលើវិស័យថាមពល និងបច្ចេកវិទ្យាអគ្គិសនី នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស។ |
| ៤ | ៣១.០៨.១០ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសជាផ្លូវការ វេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ និងការសម្ពោធគេហទំព័រផ្សព្វផ្សាយថ្មីរបស់ក្រសួងទេសចរណ៍ www.tourismcabodia.org ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ នៅសណ្ឋាគារណាហ្គាវើល។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម [illegible] | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | ឯកឧត្តម [illegible] | សមាជិកបម្រុង ក.ស.វ. |
| និពន្ធអក្ខរ ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក [illegible] | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasnaarrow@gmail.com